01600008

E464

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

Isaac Endeley
ប្រធានអង្គភាពគាំពារការពារក្តី
ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៩

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 24-Jan-2019, 13:49
CMS/CFO: Sann Rada

**គោរពជូន:** ប្រធាន និងចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង
ប្រធាន និងចៅក្រមទាំងអស់នៃអង្គជំនុំជម្រះតុលាការកំពូល

**កម្មវត្ថុ: ការចាត់តាំងសហមេធាវីបរទេសថ្មី តំណាងឲ្យលោក នួន ជា នៅក្នុងសំណុំរឿង០០២/០២**

លោក និងលោកស្រីចៅក្រមជាទីគោរព

1. ខ្ញុំមានកិត្តិយសជម្រាបជូនលោក និងលោកស្រីចៅក្រមថា តាមសំណើយ៉ាងច្បាស់របស់លោក នួន ជា និងអនុលោមតាមនីតិវិធីដែលមានចែងនៅក្នុងអនុវិធាន ១១(២)(ង), (ច) និង(ឆ) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ កម្ពុជា (“អ.វ.ត.ក”) នៅថ្ងៃនេះខ្ញុំបានចាត់តាំងលោកស្រី ដូរីន ឆិន (Doreen Chen) ជនជាតិអូស្ត្រាលីឲ្យធ្វើជាសហមេធាវីបរទេសថ្មីតំណាងឲ្យលោក នួន ជា នៅគ្រប់កិច្ចដំណើរការនីតិវិធីទាំងអស់នៅចំពោះមុខ អវតក។ ការចាត់តាំងនេះធ្វើឡើងបន្ទាប់ពីសេចក្តីសម្រេចរបស់ខ្ញុំចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៨ បញ្ចប់កិច្ចសន្យាសេវាកម្មផ្នែកច្បាប់របស់អតីតសហមេធាវីបរទេសលោក Victor Koppe ជនជាតិហូឡង់ ។

2. លោកស្រី ដូរីន ឆិន មានការយល់ដឹងជ្រៅជ្រះទាក់ទងនឹងសំណុំរឿង ០០២/០២ ។ លោកស្រីធ្លាប់បម្រើការងារជាទីប្រឹក្សាច្បាប់ជាន់ខ្ពស់ក្នុងក្រុមមេធាវីការពារក្តី នួន ជា ចាប់ពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៤ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨។ លោកស្រីបានចុះឈ្មោះក្នុងបញ្ជីមេធាវីរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជានៅខែមេសា ឆ្នាំ២០១៦ ហើយនៅខែឧសភា ឆ្នាំ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់សិទ្ធិនិយាយនៅក្នុងសវនាការដែលផ្តល់លទ្ធភាពឲ្យគាត់អាចសួរដេញដោលសាក្សីនៅក្នុងតុលាការ និងជួយសហមេធាវីក្នុងការបង្ហាញភស្តុតាងអំឡុងពេលនៃការជំនុំជម្រះក្តីក្នុងសំណុំរឿង ០០២/០២។ លោកស្រីបានដើរតួរយ៉ាងសំខាន់នៅក្នុងការរៀបចំ និងសម្របសម្រួលសារណាបិទការការពិក្សាដេញដោលនៅក្នុងសវនាការជំនុំជម្រះក្តីលោក នួន ជា ។ លោកស្រីមាន

I.E.

ការយល់ដឹងយ៉ាងច្បាស់អំពីសំណុំរឿង ច្បាប់ និងយុត្តិសាស្ត្ររបស់ អវតក ហើយលោកស្រីជាបុគ្គលសាកសមបំផុតក្នុងការដឹកនាំបណ្ដឹងសារទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។ ជាពិសេសលោកស្រីបានបង្កើតទំនាក់ទំនងធ្វើការយ៉ាងល្អជាមួយលោក នួន ជា និងក្រុមការពារក្ដី ។

3. ខ្ញុំបានពិនិត្យផ្ទៀងផ្ទាត់ថាលោកស្រី ដូរីន ធិន នៅតែជាសមាជិកដែលមានកេរ្ដិ៍ឈ្មោះល្អនៅគណៈមេធាវីកម្ពុជា និងនៅគណៈមេធាវីនៃប្រទេសរបស់គាត់ the Law Society of New South Wales នៃប្រទេសអូស្ត្រាលី ។ បើតាមខ្ញុំដឹង និងតាមការយល់ឃើញរបស់ខ្ញុំ ពុំមានទំនាស់ផលប្រយោជន៍ជាក់ស្ដែង ឬអាចកើតឡើងណាមួយដែលធ្វើឱ្យប៉ះពាល់ដល់ការចាត់តាំងលោស្រី ដូរីន ធិន ជាសហមេធាវីសម្រាប់លោក នួន ជា ឡើយ ។ នៅពេលនេះលោកស្រី ដូរីន ធិន បានចុះហត្ថលេខាលើកិច្ចសន្យាផ្ដល់សេវាកម្មផ្នែកច្បាប់ជាមួយអង្គការសហប្រជាជាតិ និងត្រូវធ្វើការជាមួយសហមេធាវីជាតិ លោក សុន អារុណ។

4. អាស្រ័យហេតុនេះ ខ្ញុំសូមស្នើលោកនិងលោកស្រីចៅក្រមទទួលស្គាល់លោកស្រី ដូរីន ធិន ជាសហមេធាវីបរទេសសម្រាប់លោក នួន ជា ។

សូមលោក និងលោកស្រីចៅក្រមទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ

Isaac Endeley

ប្រធានអង្គភាពគាំពារការពារក្ដី

**ចម្លងជូន:** **លោក ក្រាញ់ តូនី ប្រធានស្ដីទីការិយាល័យរដ្ឋបាល**

**លោក** Knut Rosandhaug, **អនុប្រធានការិយាល័យរដ្ឋបាល/អ្នកសម្របសម្រួល** UNAKRT

**លោក** Rajeev Kumra, **មន្ត្រីជាន់ខ្ពស់គ្រប់គ្រងកម្មវិធី**

**លោក សុន អារុណ សហមេធាវីជាតិឱ្យលោក នួន ជា**

**ភ្ជាប់ជាឧបសម្ព័ន្ធ៖** ទម្រង់៧៖ សំណើសុំចាត់តាំងសហមេធាវីដែលចុះហត្ថលេខាដោយលោក នួន ជា